ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១២៨០២ អពដ

ថ្ងៃ ព្រហស្បតិ៍ ១១រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកែតម្រូវបញ្ជិកាគណនេយ្យនិងលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត និងកាតព្វកិច្ចផ្តល់របាយការណ៍សវនកម្មឯករាជ្យរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ

អនុលោមតាមប្រកាសលេខ ១១៣០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរបស់សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ និងប្រកាសលេខ ៧៤១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១៨ ស្តីពីវិធាននិងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល និងពន្ធអាករនានាទាក់ទិននឹងសកម្មភាព កាត់ ដេរ និងតម្រឹម របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរទាំងអស់ឱ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារកត់សម្គាល់ឃើញថា មានសហគ្រាសមួយចំនួនបានធ្វើការកែតម្រូវបញ្ជិកាគណនេយ្យ លិខិតប្រកាសពន្ធ និងផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ ដើម្បីបញ្ជាក់អំពីអនុលោមភាពសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ទទួលបានការលើកទឹកចិត្តការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ រហូតដល់ដំណាច់ឆ្នាំ២០២២ និងត្រូវបានទទួលស្គាល់ជាសហគ្រាសផ្គត់ផ្គង់សេវា កាត់ ដេរ និងតម្រឹម (CMT)។ ដោយឡែក មានសហគ្រាសមួយចំនួនទៀតដែលកាន់បញ្ជិកាគណនេយ្យនិងលិខិតប្រកាសពន្ធមិនត្រឹមត្រូវ នៅពុំទាន់បានធ្វើការកែតម្រូវបញ្ជិកាគណនេយ្យ កែតម្រូវលិខិតប្រកាសពន្ធ និងពុំទាន់ផ្តល់របាយការណ៍សវនកម្មឯករាជ្យ ដើម្បីដាក់ជូនអគ្គនាយកដ្ឋានពន្ធដារនៅឡើយ ដែលអាចធ្វើឱ្យសហគ្រាសទាំងនោះ បាត់បង់នូវសិទ្ធិទទួលបានការអនុគ្រោះស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល បាត់បង់លក្ខខណ្ឌដើម្បីទទួលស្គាល់ជាសហគ្រាសផ្គត់ផ្គង់សេវា កាត់ ដេរ និងតម្រឹម អាចត្រូវបានចាត់ទុកជាសហគ្រាសមានអនុលោមភាពសារពើពន្ធកម្រិតទាប ព្រមទាំងទទួលរងនូវទោសទណ្ឌនានាតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ដើម្បីពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងចៀសវាងការបាត់បង់សិទ្ធិទទួលបានអត្ថប្រយោជន៍ក៏ដូចជាទទួលរងទោសទណ្ឌ ដូចបានរៀបរាប់ខាងលើ អគ្គនាយកដ្ឋានពន្ធដារសូមក្រើនរំលឹកដល់លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរទាំងឡាយណាដែលពុំទាន់ធ្វើការកែតម្រូវ អញ្ជើញមកធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យនិងលិខិតប្រកាសពន្ធក្នុងរយៈពេល ០៣(បី) ឆ្នាំថយក្រោយ និងផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធឱ្យបានយ៉ាងយឺតបំផុតត្រឹម **ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩**។ ក្នុងអំឡុងពេលនេះ ប្រសិនបើលទ្ធផលនៃការកែតម្រូវដែលនាំឱ្យមានប្រាក់ពន្ធត្រូវបង់ សហគ្រាសលោក លោកស្រីត្រូវបានអនុគ្រោះលើកលែងទោសទណ្ឌនានា ដែលក្នុងនោះមានពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ។ ដោយឡែក ក្នុងករណីដែលសវនករនៃអគ្គនាយកដ្ឋានពន្ធដារបានរកឃើញថា មានប្រាក់ពន្ធត្រូវបង់បន្ថែមក្នុងអំឡុងពេលធ្វើសវនកម្ម សហគ្រាសទាំងនោះនឹងមិនទទួលបានការអនុគ្រោះនេះទេ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរទាំងអស់ ពិតជាយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**